**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
PHNOM PENH WATER SUPPLY AUTHORITY

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ:..០៤៤..ល.និ.ណ.

ថ្ងៃ..សុក្រ..២កើត..ខែ...ពិសាខ......ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី...២១...ខែ..មេសា..ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
## ស្តីពីការចូលរួមដេញថ្លៃលក់ឡាយឡុងនូវអចលនទ្រព្យ សន្និធិ បរិក្ខារ និង សម្ភារចាស់បាត់បង់គុណភាព

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់អាជីវករក្នុងស្រុកទាំងអស់ឲ្យបានជ្រាបថាៈ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមានបំណងនឹងដាក់ដេញថ្លៃលក់ឡាយឡុងនូវអចលនទ្រព្យ សន្និធិ បរិក្ខារ និងសម្ភារចាស់បាត់បង់គុណភាព ដោយវិធីដេញថ្លៃ៣លើកក្នុងពេលតែមួយ។

ពាក្យស្នើសុំចូលរួមដេញថ្លៃមានលក់នៅ អង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃអង្គារ ទី២៥ ខែមេសា ឆ្នាំ២០២៣ តទៅ រៀងរាល់ម៉ោងធ្វើការ (៨:០០នាទីដល់១៦:៣០នាទី) ដល់ថ្ងៃពុធ ទី១៧ ខែឧសភា ឆ្នាំ២០២៣ ត្រឹមវេលាម៉ោង ១៦:០០នាទី ក្នុងតម្លៃ ១៦០,០០០រៀល (មួយច្បាប់)។

កាលបរិច្ឆេទបង្ហាញសម្ភារ ថ្ងៃពុធ ទី១០ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង០៩:០០នាទី។ ការដែលមិនបានចូលរួមពិនិត្យនូវសម្ភារគឺជាការទទួលខុសត្រូវរបស់អ្នកចូលរួមដេញថ្លៃផ្ទាល់។

កាលបរិច្ឆេទដេញថ្លៃ ថ្ងៃព្រហស្បតិ៍ទី១៨ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង១៤:០០នាទី នៅបន្ទប់បណ្តុះបណ្តាល នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (អគារអាជីវកម្ម ជាន់ទី២)។

គ្រប់ពាក្យសុំចូលរួមដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃយ៉ាងតិច ១០% (ដប់ភាគរយ) នៃតម្លៃកំណត់ឲ្យដេញ។ ប្រាក់កក់ធានាការដេញថ្លៃនេះអាចដកវិញបាន ក្នុងរយៈពេល២សប្តាហ៍ក្រោយពីចេញសេចក្តីសម្រេចឯកភាពពី **ឯកឧត្តមអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

សម្រាប់រាល់ព័ត៌មានលំអិត សូមអញ្ជើញទាក់ទងអង្គភាពលទ្ធកម្មដូចមានអាសយដ្ឋានខាងលើ ឬ តាមទូរស័ព្ទលេខ ០១៧ ៨១១ ៩១១។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធាន**

**ជូ ផល្លា**

ចម្លងជូនៈ
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ

អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទៈ (៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh